# Vacancy Announcement

FTB
ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា
Foreign Trade Bank of Cambodia

## ដំណឹងជ្រើសរើសបុគ្គលិក

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា (FTB) គឺជាធនាគារពាណិជ្ជក្នុងស្រុកទី១ នៅកម្ពុជាដែលទទួលបាន ការទុកចិត្តចាប់តាំងពីឆ្នាំ១៩៧៩ ។ ធនាគារ FTB បានផ្តល់ជូនអតិថិជននូវសេវាហិរញ្ញវត្ថុប្រកបដោយភាពជឿ ទុកចិត្ត និងសុវត្ថិភាពខ្ពស់ក្នុងធុរកិច្ចរបស់ខ្លួន ។ ផ្អែកលើចក្ខុវិស័យ ជាធនាគារពាណិជ្ជដែលមានការពេញចិត្ត ជាងគេក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារ FTB ប្តេជ្ញាបន្តគាំទ្រធុរកិច្ចរបស់អតិថិជនឲ្យកាន់តែរីកចម្រើនលូត លាស់ និងផ្តល់ជូនគ្រប់បុគ្គលិកនូវឱកាសអាជីពការងារ ដែលមានស្ថិរភាពយូរអង្វែងផងដែរ ។ ធនាគារកំពុង បន្តពង្រីកនូវវិសាលភាពប្រតិបត្តិការរបស់ខ្លួន និងពង្រឹងសមត្ថភាពបុគ្គលិកដើម្បីជួយទ្រទ្រង់នូវការរីកចម្រើន ប្រកបដោយចីរភាពយូរអង្វែង។ ទន្ទឹមនឹងការពង្រីកប្រតិបត្តិការនេះធនាគារយើងខ្ញុំ កំពុងស្វែងរកនូវបេក្ខភាព ដែលមានគុណវុឌ្ឍិ និងឆន្ទៈខ្ពស់ ដើម្បីចូលរួមជាមួយធនាគារ FTB "**និយោជកដ៏ប្រសើរនិងឈានមុខ**" សម្រាប់ មុខងារខាងក្រោម៖

## បុគ្គលិកផ្នែកអភិវឌ្ឍន៍ដៃគូពាណិជ្ជកម្ម

**(ចំនួន ០១ នាក់ បម្រើការនៅការិយាល័យកណ្តាល-ភ្នំពេញ)**

### កិច្ចការចម្បងៗ និងការទទួលខុសត្រូវ

- ធ្វើការស្វែងរកដៃគូអាជីវកម្ម និងរៀបចំបញ្ចូលទៅក្នុងប្រព័ន្ធ សម្រាប់ភាពជាដៃគូដើម្បីធ្វើការទំនាក់ទំនង
- រៀបចំផែនការ ណាត់ជួប និងចុះជួបអាជីវករ និងពាណិជ្ជករដែលជាអតិថិជនគោលដៅដើម្បីណែនាំអំពីផលិតផល និងសេវាកម្ម របស់ធនាគារ
- ការងារចម្បងគឺចុះជួបអតិថិជនជាអាជីវករ និងពាណិជ្ជករជាប្រចាំ ព្រមទាំងស្វែងរកដៃគូពាណិជ្ជកម្មបន្ថែម
- ត្រួតពិនិត្យប្រតិបត្តិការបរិមាណអាជីវករ និងជួយអ្នកគ្រប់គ្រងក្នុងការបង្កើតយុទ្ធសាស្ត្រ ដើម្បីរក្សាអាជីវករដែលសមស្រប និងកាត់បន្ថយនូវការខូចគុណភាព
- ពង្រឹងទៅលើគុណភាពសេវាកម្ម និងបង្កើនការស្វែងរកដៃគូអាជីវកម្ម និងពាណិជ្ជកម្ម
- ចុះជួយគាំទ្រដល់ការទំនាក់ទំនងលក់នៅតាមបណ្តាសាខារបស់ធនាគារ ដើម្បីជម្រុញកំនើនដៃគូអាជីវកម្ម និងពាណិជ្ជកម្មឲ្យមានសន្ទុះ កើនឡើងយ៉ាងឆាប់រហ័ស
- ជួយក្នុងការស្វែងរកពីទីផ្សារដៃគូពាណិជ្ជកម្ម និងតាមដានការអនុវត្តក្នុងក្រុមដើម្បីសម្រេចបាននូវគោលដៅលក់
- ការងារផ្សេងៗទៀតទៅតាមការចាត់តាំងរបស់ថ្នាក់គ្រប់គ្រង

### លក្ខណសម្បត្តិ និងបទពិសោធន៍

- បរិញ្ញាបត្រ ផ្នែកធនាគារ ហិរញ្ញវត្ថុ ឬផ្នែកផ្សេងៗដែលពាក់ព័ន្ធ
- លើកទឹកចិត្តដល់និស្សិតដែលទើបបញ្ចប់ការសិក្សាអាចធ្វើការដាក់ពាក្យបាន
- មានជំនាញ និងសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងល្អជាមួយអតិថិជនបានគ្រប់កម្រិត
- មានការលើកទឹកចិត្ត និងជម្រុញដល់ក្រុមការងារឲ្យសម្រេចទៅដល់គោលដៅរួម
- ជំនាញក្នុងការទំនាក់ទំនង និងរៀបចំឯកសារ
- មានចំណេះដឹងអំពីដំណើរការនៃការលក់ តាំងពីការចាប់ផ្តើម រហូតដល់បិទការលក់
- មានចំណង់ចំណូលចិត្តខ្ពស់ក្នុងការធ្វើការងារជាក្រុម និងអាចដោះស្រាយបញ្ហាបានល្អ

### របៀបដាក់ពាក្យ

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមអញ្ជើញផ្ញើប្រវត្តិរូបសង្ខេប (មានបិទរូបថត 4x6) ជាមួយលិខិតអមជាភាសាខ្មែរ/អង់គ្លេសមក ធនាគារតាមរយៈអ៊ីម៉ែល: **hr@ftbbank.com** ឬការិយាល័យកណ្តាល ស្ថិតនៅអគារលេខ ៣៣C-D ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ ឬតាមសាខាណាមួយ របស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ។

មានតែបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងត្រូវបានជាប់ក្នុងបញ្ជីសម្រាំង និងត្រូវបានទូរសព្ទអញ្ជើញឲ្យមកចូលសម្ភាសន៍ ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់លេខទូរសព្ទ **០៨១ ៦៦៦ ៥៩៧/០៨១ ៦៦៦ ៥៣៥**

វិនិយោគដើម្បីអនាគត
Investing in the future

☎ : 023 862 111
E-mail: hr@ftbbank.com
www.ftbbank.com
f : www.facebook.com/ftbcambodia